ទំនុកដំកើង៤៦-៤៨

# ជំពូក ៤៦

***ឆាចចនា*** *ព្រះជាម្ចាស់ជាទីជ្រកកោន*
*បទចម្រៀងសម្រាប់រាជ្យសហស្សវត្សរ៍*

គម្ពីរទំនុកដំកើងជំពូក៤៦ ៤៧ និង៤៨ ចងក្រងជាបទទំនាយស្តីពីព្រះអម្ចាស់យេស៊ូវយាងមកតាំងរាជ្យរបស់ទ្រង់នៅលើផែនដីយើងនេះ។ ដោយឡែក ជំពូក៤៥ បរិយាយពីសណ្ឋាននៃរាជ្យសហស្សវត្សរ៍របស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ តើនៅក្នុងរាជ្យសហស្សវត្សរ៍របស់ព្រះអម្ចាស់យេស៊ូវមានអ្វីខ្លះកើតឡើង? ឯជំពូក៤៦ ជាទំនុករបស់កូនចៅលោកកូរេ លើកសម្រាប់មេភ្លេង ត្រូវច្រៀងដោយសម្លេងស្រួច។ សម្លេងស្រួចក្នុងភាសាហេព្រើរហៅថា អែលឡាម៉ោះ ប្រែថា ព្រហ្មចារី។ ដូច្នេះ សម្លេងស្រួចក្នុងអត្ថបទនេះ មានន័យថា ជាសម្លេងរបស់នារីព្រហ្មចារី។ គម្ពីរនេះ ជាបទចម្រៀងមួយក្នុងចំណោមបទចម្រៀងឯទៀត ដែលលោកស្រីម៉ារាម ត្រូវជាបងស្រីរបស់លោកម៉ូសេ និងលោកអើរ៉ុនច្រៀងសរសើរតម្កើងដល់ព្រះជាម្ចាស់ បន្ទាប់ពីសាសន៍អ៊ីស្រាអែលបានឆ្លងសមុទ្រក្រហមរួចមក។ សេចក្តីនោះ មានរៀបរាប់ក្នុងគម្ពីរនិក្ខមនំ១៥:២១ ដែលសម្តែងថា "ម៉ារាមនាងក៏ទទួលពាក្យឆ្លើយនឹងគេថា ចូរច្រៀងថ្វាយព្រះយេហូវ៉ា ដ្បិតទ្រង់មានជ័យជំនះយ៉ាងឧត្តម ទ្រង់បានផ្តួលទាំងសេះទាំងអ្នកជិះទៅក្នុងសមុទ្រ"។

ពួកសាសន៍អ៊ីស្រាអែលនាំគ្នាច្រៀងសរសើរព្រះជាម្ចាស់ ព្រោះជោគជ័យដែលទ្រង់បានប្រទានមកដល់គេ។

នៅពេលឆ្លងកាត់គ្រាមហាទុក្ខ សាសន៍អ៊ីស្រាអែលសេសសល់ ទទួលការរងទុក្ខវេទនាយ៉ាងខ្លាំង។ កំពុងតែគេរងទុក្ខយ៉ាងសែនវេទនានោះ ព្រះអម្ចាស់យេស៊ូវយាងមកជាលើកទីពីរ ដើម្បីរំដោះសាសន៍នោះអោយរួចពីសេចក្ដីវេទនារបស់ខ្លួន។ អ្នកទាំងនោះនឹងច្រៀងបទទំនុកដំកើងជំពូក៤៦ សម្ដែងពីសេចក្ដីអបអរសាទរ និងមោទនភាពចំពោះព្រះជាម្ចាស់ដែលទ្រង់បានធ្វើសម្រាប់ពួកគេ។ ដូច្នេះ ដើម្បីអោយយើងយល់ខ្លឹមសារនៃបទគម្ពីរដែលយើងសិក្សាថ្ងៃនេះ យើងត្រូវសិក្សាជាមួយគ្នានូវគម្ពីរទំនុកដំកើងជំពូក៤៥ ៤៦ ៤៧ និង៤៨។ ការចោះយកបទគម្ពីរណាមួយក្នុងបួននេះ មកបកស្រាយដាច់ដោយឡែក ធ្វើអោយការអនុវត្តន៍ខ្លឹមសារនៃបទគម្ពីរទាំងនោះ ប្រាសចាកទាំងស្រុងខុសពីគំនិតដើម។ ដើម្បីបកស្រាយព្រះគម្ពីរអោយបានត្រឹមត្រូវ យើងមិនត្រូវដកខគម្ពីរចេញពីបរិបទដើមជាដាច់ខាត។

គម្ពីរទំនុកដំកើងជំពូក៤៦ បរិយាយពីលក្ខណៈបីយ៉ាងរបស់ព្រះជាម្ចាស់។ ទីមួយ ភាពគ្រប់គ្រាន់របស់ព្រះអង្គ ទីពីរ សុវត្ថិភាពនៅក្នុងទ្រង់ និងទីបី បរិមានុភាពនៃព្រះអម្ចាស់ដែលប្រែថា ព្រះអង្គមានភាពខ្ពស់លើសអ្វីទាំងអស់។

## ភាពគ្រប់គ្រាន់នៃព្រះអម្ចាស់

**១ព្រះទ្រង់ជាទីពឹងជ្រក ក៏ជាកំឡាំងនៃយើងខ្ញុំ ជាជំនួយដែលនៅ
ជាប់ជាមួយក្នុងគ្រាអាសន្ន ២ហេតុនោះ យើងខ្ញុំនឹងមិនខ្លាចឡើយ
ទោះបើផែនដីប្រែប្រួលទៅ ហើយភ្នំទាំងប៉ុន្មានត្រូវរើធ្លាក់ចុះនៅ
កណ្តាលសមុទ្រក៏ដោយ ៣ទោះបើទឹកសមុទ្របញ្ចេញសូរគឹកកង
ហើយរំជួលឡើង ឬភ្នំទាំងឡាយត្រូវកក្រើកញ័រ ដោយរលក
លោតចុះឡើងក្តី -បង្អង់ (ទំនុកដំកើង៤៦:១-៣)។**

សេចក្តីសន្យាខាងលើ ជាសេចក្តីពិតដែលព្រះជាម្ចាស់បានសន្យាដល់យើងគ្រប់គ្នាជាមនុស្សលោក។ ព្រះអង្គមានបន្ទូលបន្ថែមនៅក្នុងគម្ពីរទំនុកដំកើង៣៤:៨ ទាក់ទងនឹងសេចក្តីខាងលើថា "ឱសូមភ្លក់មើលឱ្យដឹងថា ព្រះយេហូវ៉ាទ្រង់ល្អចុះ មានពរហើយ មនុស្សណាដែលពឹងជ្រកក្នុងទ្រង់"។ ចំណែកព្រះអម្ចាស់យេស៊ូវមានបន្ទូលពីព្រះឱស្ឋទ្រង់ផ្ទាល់ ក្នុងគម្ពីរយ៉ូហាន៧:១៧ដែរថា "បើអ្នកណាចង់ធ្វើតាមព្រះហឫទ័យទ្រង់ នោះនឹងបានដឹងជាសេចក្តីបង្រៀននេះមកពីព្រះ ឬជាខ្ញុំនិយាយដោយអាងខ្លួនខ្ញុំ"។ នៅក្នុងគ្រាមានទុក្ខលំបាក លោកអ្នកមានលទ្ធភាពអាចយកព្រះជាម្ចាស់ជាទីទុកចិត្តរបស់លោកអ្នក។ គ្រីស្ទបរិស័ទភាគច្រើន មិនសូវទុកចិត្តព្រះអង្គប៉ុន្មានទេ ពិសេសពេលគេជួបនឹងទុក្ខលំបាក។ គេមិនទទួលស្គាល់ថា ព្រះជាម្ចាស់មានភាពគ្រប់គ្រាន់ល្មមសម្រាប់ជីវិតគេ។ យើងត្រូវការព្រះជាម្ចាស់ ដ្បិតទ្រង់មិនដែលបណ្តោយអោយយើងទទួលបរាជ័យក្នុងជីវិតឡើយ។ ព្រះអង្គទ្រង់ជាព្រះដែលមានភាពគ្រប់គ្រាន់ គ្រប់ស្ថាន

ភាពនៃជីវិតដែលយើងចាំបាច់ត្រូវឆ្លងកាត់។

"ទោះបើផែនដីប្រែប្រួលទៅ"។ ពេលខ្លះយើងត្រូវឆ្លងកាត់បទពិសោធន៍ត្រូវគេដកហូតដីដែលយើងឈរពីក្រោមជើងយើងទៅ។ ពេលនោះ តើយើងមានអារម្មណ៍យ៉ាងណាដែរ? តើលោកអ្នកធ្លាប់ឈរនៅលើខ្យល់ដែរឬទេ? មនុស្សជាច្រើនតែងគិតថា ទុក្ខលំបាករបស់គេខ្លាំងជាងទុក្ខលំបាករបស់អ្នកដទៃ។ តាមពិត មនុស្សគ្រប់រូបត្រូវឆ្លងទុក្ខលំបាកមានទំហំដូចៗគ្នា។ ចំពោះរាស្ត្ររបស់ព្រះជាម្ចាស់ កាលណាយើងទុកចិត្តលើភាពគ្រប់គ្រាន់របស់ព្រះជាម្ចាស់ហើយ ទុក្ខលំបាកដែលយើងត្រូវឆ្លងកាត់មិនជាធ្ងន់ធ្ងរខ្លាំងពេកទេ។ ព្រះអម្ចាស់ទ្រង់ជាទីពឹងជ្រក ទ្រង់ជាកម្លាំង ទ្រង់ជាអង្គជំនួយសម្រាប់ជួយយើងក្នុងពេលយើងជួបទុក្ខលំបាក។ ជនានុជនដែលធ្លាប់រស់លើពិភពលោករបស់ព្រះជាម្ចាស់កន្លងមក ក៏ដូចជាអ្នកដែលធ្លាប់រស់ពឹងពាក់លើព្រះអម្ចាស់សព្វថ្ងៃដែរ គេរកឃើញថា ព្រះបន្ទូលព្រះអង្គត្រង់ចំណុនេះពិតជាត្រឹមត្រូវ។

## សុវត្ថិភាពក្នុងព្រះអម្ចាស់

**មានទន្លេ១ដែលព្រែកទាំងប៉ុន្មាន នាំឱ្យក្រុងនៃព្រះមានសេចក្ដីអំណរ គឺជាទីបរិសុទ្ធនៃពន្លារបស់ព្រះដ៏ខ្ពស់បំផុត (ទំនុកដំកើង ៤៦:៤)។**

ខ្ញុំជឿថាទន្លេនេះ ជាទន្លេដែលព្រះជាម្ចាស់ផ្តល់អោយវិញ្ញាណរបស់យើង មានភាពល្អេល្អើយ ដោយសារការអាន និងការអនុវត្តន៍តាមព្រះបន្ទូលរបស់ព្រះអង្គ។ គម្ពីរទំនុកដំកើងជំពូក១សម្តែងថា មានពរហើយ ជនណាដែលទុកចិត្តដល់ព្រះអម្ចាស់ ដ្បិតអ្នកនោះ ប្រៀបឧបមាដូចជាដើមឈើដែលដុះនៅក្បែរផ្លូវទឹក។ ទឹកគឺជាព្រះបន្ទូលរបស់ព្រះជាម្ចាស់។ គម្ពីរអេសេគាលជំពូក៤៧សម្តែងពីដំណើរនោះ។ ចំណែកគម្ពីរវិវរណៈ២១:១ ក៏សម្តែងថាទឹក គឺជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែរ។

**៥ព្រះទ្រង់គង់នៅកណ្តាល ហើយទីក្រុងនោះមិនត្រូវរង្គើឡើយ ព្រះទ្រង់នឹងជួយចាប់តាំងពីព្រលឹមផង ៦អស់ទាំងសាសន៍ដទៃបានជ្រួលជ្រើម ហើយនគរទាំងប៉ុន្មានពពាក់ពពូនឡើង តែទ្រង់បញ្ចេញព្រះសូរសៀង នោះផែនដីក៏រលាយទៅ ៧ព្រះយេហូវ៉ានៃពួកពលបរិវារ ទ្រង់គង់នៅជាមួយនឹងយើងខ្ញុំ គឺព្រះនៃយ៉ាកុបទ្រង់ជាទីពឹងជ្រករបស់យើងខ្ញុំ -បង្អង់ (ទំនុកដំកើង៤៦:៥-៧)។**

ខខាងលើ និយាយឆ្ពោះទៅកាន់ភាពច្របូកច្របល់ ដែលត្រូវកើតឡើងក្នុងគ្រាមហាទុក្ខ។ នៅគ្រានោះ ភាពខ្មៅងងឹតគ្របបាំងសកលលោកទាំងមូល។ មនុស្សអាក្រក់ចម្រើនកម្លាំងដៃរបស់គេគ្រប់វិនាទី។ គេគំរាមកំហែងដល់សេចក្តីសុខនៅក្នុងពិភពលោកយើង។ ប៉ុន្តែ ទោះជាយ៉ាងនោះក៏ដោយ រាស្ត្ររបស់ព្រះអង្គសេសសល់

ទាំងអម្បាលមាណ អាចច្រៀងសរសើរតម្កើងដល់ព្រះអង្គថា “ព្រះទ្រង់គង់នៅកណ្តាល ហើយទីក្រុងនោះមិនត្រូវរង្គើឡើយ ព្រះទ្រង់នឹងជួយចាប់តាំងពីព្រលឹមផង”។

## បរិមានុភាពនៃព្រះអម្ចាស់

**៨ ចូរមកពិចារណាមើលអស់ទាំងការនៃព្រះយេហូវ៉ា ជាការហិន
វិនាស ដែលទ្រង់បានធ្វើនៅផែនដី ៩ ទ្រង់បណ្តាលឲ្យការសង្គ្រាម
ស្ងប់រំងាប់រហូតដល់ចុងផែនដី ទ្រង់បំបាក់ធ្នូ ហើយកាច់លំពែង ក៏
ដុតអស់ទាំងរទេះចំបាំងនៅក្នុងភ្លើង (ទំនុកដំកើង៤៦:៨-៩)។**

ព្រះមែស៊ី ឬជាព្រះអង្គសង្គ្រោះរបស់យើង នឹងយាងមកកាត់ទោសដល់ពិភពលោកយើងនេះ។ នៅពេលព្រះអង្គយាងមក ព្រះអង្គបង្ក្រាបអស់ទាំងមឹកទាំងអម្បាលមាណ ព្រមទាំងធ្វើអោយគ្រឿងសព្វាវុធរបស់គេត្រូវខូចខាតខ្ទេចខ្ទីអស់គ្មានសល់អ្វីឡើយ។ រូបភាពខាងលើ បង្ហាញពីហេតុការណ៍ដែលត្រូវកើតឡើងក្នុងគ្រាចុងក្រោយបង្អស់លើពិភពលោកយើង ដូចហោរាដានីយ៉ែលបានទាយទុកក្នុងគម្ពីរដានីយ៉ែល២:៤៥។ ជ័យជំនះរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ ដែលទ្រង់ទទួលបានក្នុងពេលនោះ ញាំងអោយមនុស្សកោតខ្លាចដល់ព្រះអង្គ។ នៅពេលនោះ សេចក្តីសុចរិត និងសេចក្តីមានពរដ៏ពិត ត្រូវកើតឡើងដល់ពិភពលោកយើង។ ព្រះអម្ចាស់យេស៊ូវ

យាងមកលើកទីពីរ ដើម្បីដកអស់ពួកទទឹងច្បាប់ទាំងអម្បាលមាណចេញពីផែនដី ដែលទ្រង់បានបង្កើត។

**"[១០] ចូរបង្អង់សិន ឱ្យបានដឹងថា អញជាព្រះ អញនឹងបានថ្កើងឡើងនៅកណ្ដាលពួកសាសន៍ដទៃ អញនឹងបានថ្កើងឡើងនៅផែនដី [១១] ព្រះយេហូវ៉ានៃពួកពលបរិវារ ទ្រង់គង់នៅជាមួយនឹងយើងខ្ញុំ ព្រះនៃយ៉ាកុបជាទីពឹងជ្រកនៃយើងខ្ញុំ -បង្អង់ (ទំនុកដំកើង៤៦: ១០-១១)។**

សេចក្ដីទាមទារដែលព្រះជាម្ចាស់ចង់បានពីយើងនៅផែនដីនេះ គឺព្រះអង្គចង់អោយអ្វីៗទាំងអស់សរសើរតម្កើងដល់ទ្រង់។

"ចូរបង្អង់សិន ឱ្យបានដឹងថា អញជាព្រះ"។ បើយើងទុកចិត្តយ៉ាងពេញទំហឹងដល់ព្រះជាម្ចាស់ ក្នុងគ្រាឆ្លងទុក្ខលំបាកយើងពិតជាចេះសប្បាយជាមួយព្រះអង្គ។ ឯការសប្បាយនេះទៀតសោត ជាការសប្បាយដែលផុសចេញពីក្នុងដួងចិត្ត។ បច្ចុប្បន្ន ខ្យល់ព្យុះជីវិតបានបក់បោកមកលើលោកអ្នកយ៉ាងខ្លាំង។ ពិភពលោកដែលយើងរស់នៅសព្វថ្ងៃ ជាពិភពលោកដែលរំជើបរំជួលគ្រប់គ្រងដោយមនុស្សអាក្រក់។ បរិស្ថានធម្មជាតិមានការប្តូរផ្លាស់យ៉ាងខ្លាំង។ រៀងរាល់ថ្ងៃ យើងឮពីការកក្រើកដី ពីសង្គ្រាមដែលកើតមានឡើង។ ឯយើង យើងត្រូវទុកចិត្តដល់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដ្បិតព្រះអង្គទ្រង់

ជាព្រះ។ ទ្រង់ធ្វើអោយយើងមានសេចក្ដីសុខសាន្តក្នុងពេលជួបប្រទះខ្យល់ព្យុះនៃជីវិត។ ព្រះអម្ចាស់យេស៊ូវយាងជាមួយពួកសិស្សទ្រង់ ពេលដែលពួកសិស្សជួបនឹងខ្យល់ព្យុះបក់គំហុកមកនៅលើទូករបស់ពួកលោក។ នៅពេលនោះព្រះអម្ចាស់យេស៊ូវតើនឡើង ហើយបង្ក្រាបដល់ខ្យល់ព្យុះនោះ។ ខ្យល់ព្យុះស្ដាប់តាមព្រះអង្គដូចកូនក្មេងស្ដាប់ម្ដាយវា។ ពួកសិស្សរបស់ទ្រង់ មានចិត្តច្រួលច្របល់ពេលជួបខ្យល់ព្យុះក្នុងជីវិត។ យើងគ្រប់គ្នាមានលក្ខណៈមិនខុសពីពួកសិស្សរបស់ទ្រង់ប៉ុន្មានទេ។ នៅពេលយើងជួបទុក្ខលំបាក យើងខ្វះការអត់ធ្មត់ក្នុងការទុកចិត្តដល់ព្រះអង្គខ្លាំងណាស់។

ជំពូក៤៦ សម្ដែងពីព្រះពរដែលត្រូវកើតឡើងក្នុងគ្រាអនាគត។ ទោះជាយ៉ាងនោះក៏ដោយ បទគម្ពីរនេះជាការលើកទឹកចិត្ត និងជាព្រះពរសម្រាប់រាស្ត្ររបស់ព្រះអង្គគ្រប់រូប ដែលរស់ក្នុងពេលបច្ចុប្បន្ននេះដែរ។

# ជំពូក ៤៧

*ឯកឧទ្ទេសនា បទចម្រៀង និងការថ្វាយបង្គំនៅក្នុងរាជ្យសហសវត្សរ៍*

គម្ពីរទំនុកដំកើងជំពូក៤៧ ស្ថិតនៅក្នុងចង្កោមបទទំនាយដែលទាក់ទងនឹងរាជ្យសហស្សវត្សរ៍របស់ព្រះអម្ចាស់យេស៊ូវ។ ទ្រង់យាងមកតាំងរាជ្យនោះនៅលើផែនដីយើងនេះ។ នៅគ្រានោះ មានការច្រៀងចម្រៀងបទថ្មី និងការថ្វាយបង្គំអង្គព្រះយេស៊ូវគ្រីស្ទ ជាលក្ខណៈសកល។ យើងជាអ្នកជឿត្រូវចាប់ផ្តើមថ្វាយបង្គំព្រះអង្គពីគ្រាដែលយើងស្គាល់ទ្រង់រហូតដល់គ្រារស់កល្បជានិច្ច។

> **[១]ម្នាល ជនទាំងឡាយអើយ ចូរទះដៃទាំងអស់គ្នាចុះ ចូរស្រែកហ៊ោថ្វាយព្រះ ដោយសំឡេងជាជ័យជំនះ [២]ដ្បិតព្រះយេហូវ៉ាដ៏ខ្ពស់បំផុត ទ្រង់គួរស្ញែងខ្លាច ទ្រង់ជាមហាក្សត្រយ៉ាងធំលើផែនដីទាំងមូល (ទំនុកដំកើង៤៧:១-២)។**

ព្រះអម្ចាស់យេស៊ូវនឹងយាងមកគ្រប់គ្រងលើផែនដីទាំងមូល។ ដូច្នេះហើយ បានជាព្រះអង្គស័ក្តិសមនឹងទទួលការសរសើរ និងការថ្វាយបង្គំពីយើងដែលជាអ្នកជឿ

ដល់ព្រះអង្គ។

នៅលើផែនដីនេះ មានការបះបោរ មានកិរិយាអាត្មានិយម មានមហិច្ឆតាគ្រប់បែបយ៉ាងនិងអនីតិភាពនៅក្នុងសង្គម។ ហេតុការណ៍អាក្រក់ទាំងនោះ កើតឡើងដោយសារមនុស្សលោកមានចិត្តបះបោរទាស់នឹងព្រះជាម្ចាស់។ បើលោកអ្នកបងប្អូនធុញទ្រាន់នឹងអំពើអាក្រក់គ្រប់បែបយ៉ាង សូមលោកអ្នកទុកចិត្តដល់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ចុះថា ថ្ងៃដែលព្រះអម្ចាស់យេស៊ូវយាងមកសោយរាជ្យលើផែនដីយើងនេះ ការអាក្រក់ទាំងអម្បាលមាណនោះមិនមានទៀតឡើយ។ គម្ពីរទំនុកដំកើងជំពូក១៦ សម្ដែងពីការអបអរសាទរដល់ការយាងត្រឡប់មកវិញ នៃព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ ចំណែកគម្ពីរទំនុកដំកើងជំពូក១៧ សម្ដែងពីស្ថានភាពនៃរាជ្យរបស់ព្រះអង្គដែលត្រូវតាំងនៅលើផែនដីយើង។

> **៣ ទ្រង់បង្ក្រាបជនទាំងឡាយនៅក្រោមអំណាចយើងខ្ញុំ ព្រមទាំងនគរផ្សេងៗ ឲ្យនៅក្រោមជើងយើងខ្ញុំផង ៤ គឺទ្រង់ដែលរើសមរដកឲ្យយើងខ្ញុំ គឺជាសិរីល្អរបស់យ៉ាកុប ជាអ្នកដែលទ្រង់ស្រឡាញ់ -បង្អង់ (ទំនុកដំកើង៤៧:៣-៤)។**

គ្រានោះ រាស្ត្ររបស់ព្រះជាម្ចាស់គ្រប់រូប អាចច្រៀងសរសើរតម្កើងព្រះអង្គបទ "អំណរដល់លោក ព្រះបុត្រកើតហើយ"។ បទនេះ មិនមែនជាបទចម្រៀងសម្រាប់

ប្រើនៅពេលណូអែលទេ តែជាបទចម្រៀងសម្រាប់ច្រៀងសរសើរតម្កើងព្រះអម្ចាស់យេស៊ូវ ពេលទ្រង់យាងត្រឡប់មកផែនដីនេះជាលើកទីពីរ។ នៅគ្រានោះ ផែនដីទាំងមូល មានសេចក្តីអបអររីករាយសាទរយ៉ាងខ្លាំងក្រៃឥតឧបមា។

"ចូរទះដៃទាំងអស់គ្នាចុះ ចូរស្រែកហ៊ោថ្វាយព្រះ ដោយសំឡេងជាជ័យជំនះ"។ នៅគ្រានោះ មានតែសេចក្តីអរសប្បាយ និងសេចក្តីរីករាយឥតឧបមាពីសំណាក់ជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ។

នៅពេលថ្វាយបង្គំព្រះអង្គ បើមានការទះដៃសរសើរតម្កើងព្រះអង្គ ទាំងច្រៀងដោយលោតកញ្ឆេងផង តើជាការខុសឬ? បើតាមខ្ញុំយល់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ការថ្វាយបង្គំព្រះអង្គដោយទះដៃសរសើរតម្កើងព្រះអង្គ ដោយការច្រៀងយ៉ាងសប្បាយ មានការគ្រប់គ្រងត្រឹមត្រូវ ជាកម្មវិធីល្អបំផុត។ ខ្ញុំយល់ថា ការស្ងៀមស្ងាត់ក្នុងក្រុមជំនុំដែលធ្លាប់ធ្វើកន្លងមក ច្រើនជាការស្ងៀមស្ងាត់មានលក្ខណៈដូចស្លាប់។ ការថ្វាយបង្គំព្រះអង្គ ត្រូវមានភាពអ៊ូអរអធិកអធម និងការសប្បាយរីករាយក្នុងវត្តមានរបស់ព្រះអង្គ ។

**៥ព្រះទ្រង់បានយាងឡើងដោយសំឡេងហ៊ោ គឺព្រះយេហូវ៉ាបាន**
**ឡើងទៅដោយសូរផ្លុំត្រែ ៦ចូរច្រៀងសរសើរដល់ព្រះ ចូរច្រៀង**
**សរសើរចុះ ចូរច្រៀងសរសើរដល់មហាក្សត្រនៃយើងខ្ញុំ ចូរច្រៀង**
**សរសើរចុះ ៧ដ្បិតព្រះទ្រង់ជាមហាក្សត្រលើផែនដីទាំងមូល ចូរ**

**ច្រៀងសរសើរយ៉ាងពីរោះចុះ។ ៨ព្រះទ្រង់គ្រប់គ្រងលើអស់ទាំង**
**សាសន៍ ព្រះទ្រង់គង់លើបល្ល័ង្កបរិសុទ្ធនៃទ្រង់ ៩ពួកអស់អ្នកធំនៃ**
**សាសន៍ទាំងឡាយបានប្រជុំគ្នា មកឯរាស្ត្ររបស់ព្រះនៃអ័ប្រាហាំ**
**ដ្បិតអស់ទាំងខែលនៅផែនដីជារបស់ផងព្រះ ទ្រង់បានថ្កើងឡើង**
**យ៉ាងក្រៃលែង (ទំនុកដំកើង៤៧:៥–៩)។**

"ព្រះទ្រង់បានយាងឡើងដោយសំឡេងហ៊ោ គឺព្រះយេហូវ៉ាបានឡើងទៅដោយសូរផ្លុំត្រែ"។ "ព្រះយេហូវ៉ាបានឡើងទៅ" គឺព្រះអម្ចាស់យេស៊ូវទ្រង់យាងឡើងទៅស្ថានសួគ៌វិញ បន្ទាប់ពីព្រះអង្គបានធ្វើការបញ្ចប់សេចក្តីសង្គ្រោះសម្រាប់មនុស្សលោករួចហើយ។ ព្រឹត្តិការណ៍នោះ កើតឡើងជាងពីរពាន់ឆ្នាំកន្លងទៅ។ គម្ពីរទំនុកដំកើងជំពូក២៤បរិយាយពីដំណើរនោះ។ ប៉ុន្តែ នៅក្នុងព្រះបន្ទូលរបស់ព្រះអង្គមានព្រឹត្តិការណ៍ដែលព្រះអម្ចាស់យេស៊ូវឡើងទៅដោយសូរផ្លុំត្រែ។ នៅពេលព្រះអម្ចាស់យេស៊ូវយាងមកជាលើកទីពីរ ព្រះអង្គបានតាំងរាជ្យរបស់ទ្រង់នៅលើផែនដីយើងនេះរួចហើយព្រះអង្គយាងចុះឡើង រវាងចន្លោះរាជ្យរបស់ទ្រង់នៅផែនដី និងទីក្រុងយេរូសាឡិមថ្មី។ ចំណែកឯយើងដែលជាអ្នកជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ យើងមានសិទ្ធិធ្វើដំណើរចុះឡើងចន្លោះផែនដី និងទីក្រុងយេរូសាឡិមថ្មីដូចព្រះអង្គដែរ។ នៅក្នុងរាជ្យសហស្សវត្សរ៍ ព្រះអង្គបានបើកសម្តែងអោយមនុស្សលោកឃើញសិរីល្អរបស់ទ្រង់ដែលត្រូវយាងមកតាំងលើផែនដីនេះ។

# ជំពូក ៤៨

*ប្រធានបទ ជ័យជំនះចុងក្រោយបង្អស់នៃព្រះមែស៊ី
ឬព្រះអង្គសង្គ្រោះ*

គម្ពីរទំនុកដំកើងជំពុក៤៨ ស្ថិតនៅក្នុងចង្កោមបទទំនាយដែលទាយពីរាជ្យរបស់ព្រះអម្ចាស់យេស៊ូវ ត្រូវយាងមកតាំងលើផែនដីយើងនេះ ក្នុងគ្រាមួយពាន់ឆ្នាំ។ បទនេះសម្តែងពីជ័យជំនះចុងក្រោយបង្អស់ និងជាជ័យជំនះគ្រប់លក្ខណ៍ ដែលព្រះអម្ចាស់យេស៊ូវគ្រីស្ទ ទ្រង់ទទួលបានក្នុងនាមព្រះអង្គជាអង្គសង្គ្រោះ របស់មនុស្សលោក។

**១ ព្រះយេហូវ៉ាទ្រង់ធំប្រសើរ ហើយគួរសរសើរណាស់ ក្នុងទីក្រុង
របស់ព្រះនៃយើងខ្ញុំ គឺនៅលើភ្នំបរិសុទ្ធនៃទ្រង់ ២ឯភ្នំស៊ីយ៉ូននៅ
ទិសខាងជើង នោះមានលំអដោយនៅលើទីខ្ពស់ ជាទីរីករាយចិត្ត
ដល់ផែនដីទាំងមូល គឺជាទីក្រុងនៃមហាក្សត្រដ៏ធំ ៣ព្រះទ្រង់បាន
សំដែងថា ទ្រង់ជាទីពឹងនៅក្នុងព្រះរាជវាំងនៃក្រុងនោះ (ទំនុក
ដំកើង៤៨:១-៣)។**

ទីក្រុងស៊ីយ៉ូន ឃើញសម្តែងនៅក្នុងខខាងលើ គឺភ្នំស៊ីយ៉ូនដែលស្ថិតនៅភូមិសាស្ត្រខាងកើតទីក្រុងយេរូសាឡិម។ ចំណែកភ្នំបរិសុទ្ធរបស់ព្រះអង្គវិញ គឺព្រះអង្គមានបន្ទូលពីទីក្រុងរបស់ព្រះអង្គ ពោលគឺជាទីក្រុងយេរូសាឡិមថ្មី។

ម្យ៉ាងទៀត សូមយើងកត់ចំណាំនូវឃ្លាដែលយើងឃើញនិយាយថា "នៅទិសខាងជើង"។ ឃ្លានេះនិយាយឆ្ពោះទៅកាន់មហាវិថីដែលត្រូវធ្វើដំណើរចុះឡើង រវាងរាជ្យរបស់ព្រះជាម្ចាស់ដែលតាំងនៅលើផែនដីនេះ និងទីក្រុងយេរូសាឡិមថ្មី។ ព្រះគម្ពីរអេសាយមានសម្តែងពីទិសខាងជើងនេះដែរ។ គម្ពីរនេះចែងថា "ឯងបានគិតក្នុងចិត្តថា អញនឹងឡើងទៅឯស្ថានសួគ៌ អញនឹងដំកើងបល្ល័ង្កអញ ឱ្យខ្ពស់ជាងអស់ ទាំងផ្កាយរបស់ព្រះ ហើយអញនឹងអង្គុយលើភ្នំជាទីប្រជុំជំនុំ នៅទីបំផុតនៃទិសខាងជើង អញនឹងឡើងទៅផុតទីខ្ពស់នៃពពក អញនឹងលើកខ្លួនឱ្យបានដូចជាព្រះដ៏ខ្ពស់បំផុត" (អេសាយ១៤:១៣-១៤)។ សាតាំងនឹងនាំកងទ័ពពីទិសខាងជើង មកទប់ទល់នឹងកងទ័ពរបស់ព្រះជាម្ចាស់។ ប៉ុន្តែ ផែនការរបស់វាត្រូវបរាជ័យ ពីព្រោះទ្រង់បានវាយបំបាក់វាដោយអង្គទ្រង់ផ្ទាល់។

ឥឡូវនេះ យើងឃើញមានចំបាំងចុងក្រោយបង្អស់ ដែលត្រូវកើតឡើងនៅទិសខាងជើង។

**៤ ដ្បិតមើល ពួកមហាក្សត្រទាំងប៉ុន្មានបានប្រជុំគ្នា ក៏នាំគ្នាយាង**
**ទៅតាមទីនោះ ៥ គ្រាឃើញទីក្រុង នោះក៏អស្ចារ្យក្នុងចិត្ត គេមាន**

**សេចក្តីពុកស្អុត រួចរត់ចេញបាត់ទៅ (ទំនុកដំកើង៤៨:៤-៥)។**

ខ្ញុំជឿថា ព្រឹត្តិការណ៍ដែលសម្តែងក្នុងខខាងលើ ពណ៌នាពីគ្រាបន្ទាប់ពីព្រះអម្ចាស់យេស៊ូវ សោយរាជ្យអស់រយៈពេលមួយពាន់ឆ្នាំនៅលើផែនដីយើងនេះ។ បន្ទាប់ពីគ្រាមួយពាន់ឆ្នាំទៅ មានពេលមួយដែលព្រះអម្ចាស់លែងសាតាំង និងពួកប្រព្រឹត្តអំពើអាក្រក់អោយបានបំពេញតួនាទីរបស់ខ្លួនម្តងទៀត មុននឹងព្រះអម្ចាស់ចាប់គេបោះទៅក្នុងបឹងភ្លើង ហើយត្រូវរស់នៅទីនោះអស់កល្បជានិច្ច។ គម្ពីរវិវរណៈ២០:៧-៩ សម្តែងពីព្រឹត្តិការណ៍នោះថា "លុះផុតពី១ពាន់ឆ្នាំនោះហើយ ទើបទ្រង់នឹងស្រាយអារក្សសាតាំងលែងពីគុកចេញ នោះវានឹងចេញទៅ ខំនាំអស់ទាំងសាសន៍ដែលនៅផែនដីទាំង៤ទិស ឱ្យវង្វេង គឺទាំងសាសន៍កុក នឹងសាសន៍ម៉ាកុក ដើម្បីនឹងប្រមូលគេមកច្បាំង ចំនួនគេដូចជាខ្សាច់នៃសមុទ្រ នោះគេក៏ឡើងទៅពេញពាសលើផែនដីទាំងឡោមព័ទ្ធទីដំឡើងត្រសាលរបស់ពួកបរិសុទ្ធ ហើយនឹងទីក្រុងស្ងួនភ្ងាដែរ តែមាន ភ្លើងធ្លាក់ពីលើមេឃមកអំពីព្រះ បញ្ឆេះគេទាំងអស់ទៅ"។

**នៅក្នុងទីក្រុងរបស់ព្រះនៃពួកពលបរិវារ គឺជាក្រុងរបស់ព្រះនៃយើងខ្ញុំ នោះយើងខ្ញុំបានឃើញមាន ដូចជាបានឮរៀងមកហើយ ព្រះទ្រង់នឹងតាំងទីក្រុងនោះ ឱ្យនៅជាប់ជារៀងរាបដរាបទៅ -បង្អង់ (ទំនុកដំកើង៤៨:៨)។**

កន្លងមក ក្នុងព្រះគម្ពីរសញ្ញាចាស់ ពួកហោរាបានទាយពីរាជ្យរបស់ព្រះអម្ចាស់យេស៊ូវដែលត្រូវយាងមក។ ក្នុងព្រះគម្ពីរសញ្ញាថ្មី អ្នកផ្សាយដំណឹងល្អបានប្រកាសថា ព្រះអម្ចាស់យេស៊ូវនឹងយាងមកដែរ។ ព្រឹត្តិការណ៍នោះនឹងកើតមានឡើងជាពិតប្រាកដ។ ព្រះអង្គសន្យាក្នុងព្រះបន្ទូលរបស់ព្រះអង្គរាប់រយឆ្នាំកន្លងទៅហើយថា ព្រះអង្គនឹងយាងត្រឡប់មកវិញ។ ទីបំផុត ព្រះអង្គយាងមកមែន។ ខខាងលើ សម្តែងពីធាតុពិតនៃការយាងត្រឡប់មកវិញ នៃព្រះអម្ចាស់យេស៊ូវគ្រីស្ទ។

**៩ឱព្រះអង្គអើយ នៅកណ្តាលព្រះវិហារនៃទ្រង់ នោះយើងខ្ញុំបាននឹករំពឹងពីសេចក្តីសប្បុរសរបស់ទ្រង់ ១០ឱព្រះអង្គអើយ ដែលល្បីព្រះនាមទ្រង់ បានឮសុសសាយយ៉ាងណា នោះសេចក្តីសរសើរនៃទ្រង់ក៏បានដល់ចុងផែនដីបំផុតយ៉ាងនោះដែរ ព្រះហស្តស្តាំនៃទ្រង់មានពេញដោយសេចក្តីសុចរិត (ទំនុកដំកើង៤៨:៩-១០)។**

នៅក្នុងគ្រាមួយពាន់ឆ្នាំ ពួកអ្នកជឿដល់ព្រះអម្ចាស់យេស៊ូវថ្វាយបង្គំព្រះអង្គព្រមទាំងពិចារណាពីអស់ទាំងការល្អ និងសេចក្តីស្រឡាញ់ដែលទ្រង់បានធ្វើចំពោះមនុស្សមានបាប។ ព្រះអង្គបានប្រោសលោះគេឱ្យមានជីវិតអស់កល្បជានិច្ច ព្រមទាំងអោយគេបានរស់ជាមួយព្រះអង្គអស់កល្បតរៀងទៅ។

គម្ពីរទំនុកដំកើងជំពូក៤៨ បញ្ចប់ដោយបទសរសើរយ៉ាងឱឡារិក។ ឯ

បទសរសើរនោះចែងថា:

> **[១១]គួរឱ្យក្រុងស៊ីយ៉ូនមានសេចក្តីអំណរ គួរឱ្យពួកកូនស្រីសាសន៍**
> **យូដាបានរីករាយឡើង ដោយព្រោះសេចក្តីយុត្តិធម៌របស់ទ្រង់**
> **[១២]ចូរដើរសព្វគ្រប់ក្នុងក្រុងស៊ីយ៉ូន ចូរដើរព័ទ្ធជុំវិញផង ហើយរាប់**
> **អស់ទាំងប៉មនៃទីក្រុង [១៣]ចូរសង្កេតមើលកំផែងទាំងប៉ុន្មានឱ្យមែន**
> **ទែន ហើយពិចារណាព្រះរាជវាំងនោះផង ដើម្បីនឹងថ្លែងប្រាប់**
> **ដល់កូនចៅតទៅ [១៤]ដ្បិតព្រះនេះ ទ្រង់ជាព្រះនៃយើងខ្ញុំនៅអស់**
> **កល្បជានិច្ច ទ្រង់នឹងធ្វើជាអ្នកនាំមុខយើងខ្ញុំ ដរាបដល់អស់ជីវិត**
> **ផង (ទំនុកដំកើង៤៨:១១-១៤)។**

រាស្ត្ររបស់ព្រះអង្គដើរក្នុងទីក្រុងយេរូសាឡិម មានទឹកចិត្តរីករាយសប្បាយយ៉ាងខ្លាំងក្រៃលែង។ ពេលនោះ គេសម្លឹងមើលគ្រប់ច្រកល្ហក។ គេដើរទស្សនារបស់សព្វសារពើ ដែលព្រះជាម្ចាស់បង្កើតមកយកទៅតាំងនៅទីក្រុងយេរូសាឡិម។ រាស្ត្ររបស់ព្រះអង្គថ្វាយសិរីល្អដល់ព្រះអម្ចាស់យេស៊ូវ ព្រមទាំងដល់ព្រះវរបិតា ដែលទ្រង់បានដឹកនាំជីវិតរបស់គេ ពេលគេរស់នៅលើផែនដីនេះនៅឡើយ។ បទសរសើរទាំងអម្បាលមាណនោះ ផុះឡើងចេញពីដួងចិត្តបរិសុទ្ធរបស់មនុស្សគ្រប់រូប។ បទសរសើរនោះ ជាបទសរសើរដែលមានន័យខ្លឹមសារយ៉ាងជ្រាលជ្រៅ។

យើងស្លេះការសិក្សាគម្ពីរទំនុកដំកើងត្រឹមណេះសិនចុះ។ ទំរាំយើងជួបគ្នាលើកក្រោយ សូមព្រះជាម្ចាស់ប្រទានពរដ៏ធំឧត្តម ដល់លោកអ្នកបងប្អូនគ្រប់ៗគ្នា។ "ដើរជាមួយនឹងព្រះ ពិតជាប្រទះនឹងព្រះយេស៊ូវជាមិនខាន!"